ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៥ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC




ក ស វ

**Work Activities**

ប្រចាំខែកញ្ញា ឆ្នាំ២០១២



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ | ១ |
| ២- | សេចក្តីព្រាងច្បាប់ស្តីពីការបង្ការនិងពន្លត់អគ្គីភ័យ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែសីហា ឆ្នាំ២០១២ | ៣ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

# សេចក្តីព្រាងច្បាប់ស្តីពី ការគ្រប់គ្រងគ្រោះមហន្តរាយ

កាលពីថ្ងៃទី១២ ថ្ងៃទី១៩ និងថ្ងៃទី២៥ ខែកក្កដា និងថ្ងៃទី១ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គាំង តុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។



គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងគោលបំណងគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានគោលដៅបង្កាទប់ស្កាត់មុនពេលមានគ្រោះមហន្តរាយ ជួយសង្គ្រោះក្នុងពេលមានគ្រោះមហន្តរាយ និងស្តារឡើងវិញក្រោយពេលមានគ្រោះមហន្តរាយ។

ដោយផ្អែកលើការកើតឡើងនិងវិសាលភាពនៃគ្រោះមហន្តរាយនៅព្រះរាជាណាចក្រកម្ពុជាដែលបង្កឡើងដោយធម្មជាតិគឺ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ។ល។ មុខសញ្ញាគ្រោះមហន្តរាយបង្កឡើងដោយមនុស្ស ដោយជំងឺឆ្លងផ្សេងៗទៀត និងដោយការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមមុខយ៉ាងធ្ងន់ធ្ងរដែលប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្រ។

ការកសាងសេចក្តីព្រាងច្បាប់នេះបានបញ្ចប់នៅឆ្នាំ២០០៩ និងបានដាក់ឲ្យមានការពិគ្រោះយោបល់ជាបន្តបន្ទាប់ដូចខាងក្រោម៖

- ប្រជុំដំបូងជាមួយគណៈកម្មការកសាងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- សិក្ខាសាលាជាមួយក្រសួងពាក់ព័ន្ធដែលជាសមាជិកនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងបានពិគ្រោះយោបល់ជាមួយអង្គការដៃគូ ភ្នាក់ងារអង្គការសហប្រជាជាតិ រដ្ឋបាលខេត្ត ចំនួន ១១ លើក។
- មានការជួយពិនិត្យពីអ្នកតំណាងរាស្ត្រមួយចំនួន បន្ទាប់មកក៏បានផ្ញើជូនក្រសួងពាក់ព័ន្ធ ដើម្បីផ្តល់យោបល់[១]។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

## សេចក្តីព្រាងច្បាប់ស្តីពី

# ការបង្ការនិងពន្លត់អគ្គីភ័យ

កាលពីថ្ងៃទី៧ ថ្ងៃទី២១ និងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១២ វេលាម៉ោង៨:៣០នាទី និងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **គាំង គុងហ៊ាង** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការបង្ការនិងពន្លត់អគ្គីភ័យ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងមហាផ្ទៃ ។



ក្រសួងមហាផ្ទៃបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្ការនិងពន្លត់អគ្គីភ័យក្នុងគោលបំណងកាត់បន្ថយគ្រោះមហន្តរាយដែលបង្កឡើងដោយអគ្គីភ័យ ពីមួយឆ្នាំទៅមួយឆ្នាំចេះតែមានកំណើនគួរឲ្យព្រួយបារម្ភ ដែលគំរាមកំហែងដល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់អាយុជីវិត សុខុមាលភាព ខូចខាតទ្រព្យសម្បត្តិ បរិស្ថាន និងជះឥទ្ធិពលដល់គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

យោងតាមការសិក្សាបានបង្ហាញឲ្យឃើញថា មហន្តរាយអគ្គីភ័យនេះបណ្តាលមកពីការធ្វេសប្រហែសក្នុងការប្រើប្រាស់ប្រភពភ្លើង ប្រភពបំភាយកំដៅដែលអាចបង្កើតជាភ្លើង ប្រព័ន្ធអគ្គិសនីខ្វះបច្ចេកទេស ច្រើនជាងការបង្កឡើងដោយចេតនាពីមនុស្សឬពីធម្មជាតិ។

ដោយខ្សោយប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការជួយពន្លត់ និងសង្គ្រោះកាន់តែលំបាក ដែលបណ្តាលមកពីការរីកចម្រើនផ្នែកសំណង់មានកម្ពស់ច្រើនជាន់ សំណង់ជាន់ក្រោមដី និងសំណង់ធម្មតា រួមទាំងមុខទំនិញងាយឆេះ និងផ្ទុះឆេះជាច្រើន បាននឹងកំពុងពង្រាយនិងធ្វើចរាចរទូទាំងប្រទេស ដោយយើងពុំមានបទដ្ឋានគតិយុត្តិណាបញ្ញត្តិច្បាស់លាស់អំពីលក្ខខ័ណ្ឌ វិធានការបង្ការ និងពន្លត់អគ្គីភ័យនៅឡើយ។ ដូច្នេះ សេចក្តីព្រាងច្បាប់ស្តីពីការបង្ការនិងពន្លត់អគ្គីភ័យនេះអាចរួមចំណែកយ៉ាងសំខាន់ដល់ការថែរក្សាសន្តិសុខ សុវត្ថិភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត ទ្រព្យសម្បត្តិ និងជាទូទៅចូលរួមកាត់បន្ថយភាពក្រីក្រ បង្កើនទំនុកចិត្តដល់វិនិយោគទុន និងអ្នកទេសចរ(១)។ល។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកក្កដា ឆ្នាំ២០១២*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១២នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២ ដែលដឹកនាំដោយឯកឧត្តម **យឹម ឈុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហា ឆ្នាំ២០១២ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ១,១% ធៀបនឹងខែមុន និងកើនឡើង ២,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ ការឡើងថ្លៃទំនិញប្រើប្រាស់នាខែសីហាធៀបនឹងខែមុន មានការរួមចំណែកនៃក្រុមម្ហូបអាហារ ៤៩% និង ក្រុមការដឹកជញ្ជូន ៣០%។

**បើធៀបនឹងខែដូចគ្នាឆ្នាំមុន ក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម៖**

| *ក្រុមទំនិញ* | *មុខទំនិញ* | |
|---|---|---|
| ម្ហូបអាហារ : +២,០% | អង្ករ : +៥,៩% | បន្លែ: +១៤% |
| សម្លៀកបំពាក់ និងស្បែកជើង : +៤,៦% | សាច់ជ្រូក : -៧,១% | ឧស្ម័ន: -១,៦% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន : +២,៣% | សាច់គោស្រស់: +១៣% | ប្រេងសាំង: +៤,២% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ : +៣,៣% | សាច់មាន់ : -២,៨% | ប្រេងម៉ាស៊ូត: +៤,៩% ។ |
| ការដឹកជញ្ជូន: +២,៧% | ត្រីស្រស់ : -៤,៦% | |
| ភោជនីយដ្ឋាន: +៣,១% | | |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខនៃតារាងទាំង៥ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ ( Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១បម្រែបម្រួល.សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១០–២០១២

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា^P | តុលា^P | វិច្ឆិកា^P | ធ្នូ | ប្រចាំឆ្នាំ^P |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥៨%, | ៥៤%, | ៥៤%, | ៤៨%, | ២២%, | ១៨%, | ១៣%, | ២,២% | ២,៤% | ២,៣% | ២,៣% | | ៣,១% |
| | ខែមុន | ១០, | ០៤, | ០៦%, | ០៥%, | -១១%, | ០១%, | ០ | ១,១% | ០,២% | ០,៩% | ០-,៦% | | |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦៥%, | ៧១%, | ៧១%, | ៦៤%, | ៦៧%, | ៥៣%, | ៥៦%, | ៤៩%, | ៥៥%, |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១៤%, | ០៥%, | ០៦%, | ០២%, | ១០%, | ០១%, | ៧%,០- | ៨%,០- | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |

P: តួលេខខែកញ្ញា តុលា វិច្ឆិកា និងប្រចាំឆ្នាំ២០១២ ជាតួលេខព្យាករដោយក តាមវិធីសាស្ត្រ ) .វ.ស.DECOMPOSITION )

ក្រាហ្វ ១ .បម្រែបម្រួលថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១១ និង២០១២ ( ធៀបនឹងខែដូចគ្នាឆ្នាំមុន )
ក្រាហ្វបង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ ធៀប ) នឹងខែដូចគ្នា។២០១១ និង ២០១២ ឆ្នាំ (
ក្រាហ្វក៏បង្ហាញអត្រាអតិផរណាព្យាករបីខែទៅមុខ ធៀប )នឹងខែដូចគ្នាឆ្នាំមុន( សម្រាប់ឆ្នាំ២០១២។




➡អត្រាប្តូរប្រាក់៖

| *ប្រភេទ* | អត្រាខែសីហា ២០១២ | អត្រាខែកក្កដា ២០១២ | អត្រាខែសីហា ២០១១ | *ប្រភេទ* | អត្រាខែសីហា ២០១២ | អត្រាខែកក្កដា ២០១២ | អត្រាខែសីហា ២០១១ |
|---|---|---|---|---|---|---|---|
| រដុល្លារ/ | ៤០៤៥រ១/$ | ៤០៧០រ១/$ | ៤០៩៣រ១/$ | បាតដុល្លារ/ | ៣១,៣៧បាត/១$ | ៣១,៥៨បាត/១$ | ៣០,០០បាត/១$ |
| របាត/ | ១២៩របាត១/ | ១២៩របាត១/ | ១៣៦របាត១/ | ដុងដុល្លារ/ | ២០៨៤០ដុង១/$ | ២០៨៤០ដុង១/$ | ២០៨៣០ដុង១/$ |
| រដុង/ | ០,១៩៤រដុង១/ | ០,១៩៥រដុង១/ | ០,១៩៦រដុង១/ | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែសីហាឆ្នាំ២០១២ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

- *ចំណូលថវិកាជាតិអនុវត្តបានចំនួន ៦៨១៤, ៣ន់លាន រៀលមធ្យម) ប្រចាំខែ ៧២នៃ %គម្រោង( ក្នុងនោះ* ចំណូលចរន្តចំនួន ៥៩៣,៤៣ន់លានរៀល មធ្យម )ប្រចាំខែ ១០០(នៃគម្រោង % និងចំណូលមូលធនចំនួន ៨៨ *៣ន់លានរៀល។*
- បើធៀបនឹងខែមុនចំណូលថវិកាជាតិកើនឡើង ១១% និងកើនឡើង ៣១% *ធៀបនឹងខែដូចគ្នាឆ្នាំមុន។* កំណើនធៀបនឹងខែដូចគ្នាឆ្នាំមុន ជារួមបណ្តាលមកពីចំណូលចរន្តកើនឡើង ១៥%។

ក្រាហ្វ ២និង ២០១១ ចំណូលថវិកាជាតិ ឆ្នាំ . ២០១២
(៣ន់លានរៀល)



- នៅក្នុងចំណូលចរន្តៈ
  - ✓ ចំណូលសារពើពន្ធមានចំនួន ៥១០,៦ពាន់លានរៀល ថយចុះ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។
  - ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ៨២,៨ពាន់លានរៀល កើនឡើង៥៧% ធៀបនឹងខែមុន និងកើនឡើង ២៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| ក្នុងចំណូលសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | | ក្នុងចំណូលមិនមែនសារពើពន្ធ )ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន( | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ : -១% | )+៩(% | ➢ នេសាទ : +២% | )+៤៧២%( |
| ➢ ចំណូលពន្ធដារ : -១៤% | )+២៦(% | ➢ រុក្ខាប្រមាញ់ : -៦៨% | )+៥០៥(% |
| ➢ ចំណូលសារពើពន្ធផ្សេង ៗ: -២៥% | )+១៥(% | ➢ អាកាសចរណ៍ស៊ីវិល : +៩១៦% | ) +៧(% |
| ✧ កាស៊ីណូ : -៣៧% | )-១៣%( | ➢ ផលទុនទេសចរណ៍ : +៤២៥១% | )+៦៤%( |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : -៦៩% | ) +២២%( | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : -៨៣% | )-៩០(% |
| ✧ កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ: -២% | )+៣១%( | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ): +១៤% | (+២៥%) |

- ***ចំណាយថវិកាជាតិ*** អនុវត្តបានចំនួន ៦០០ ពាន់លានរៀល )*មធ្យមប្រចាំខែ ៦២* (*នៃគម្រោង* %ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៥២០ពាន់លានរៀល )*មធ្យមប្រចាំខែ ៩៣*និង (*នៃគម្រោង* %**ចំណាយមូលធន**ចំនួន ៧៩ ពាន់លានរៀល។

- *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ៣៩% និងថយចុះ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តថយចុះ៤២% ធៀបនឹងខែមុន និងថយចុះ១៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ**ចំណាយមូលធន** ថយចុះ១៥% ធៀបនឹងខែមុន និងថយចុះ៤៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

- *ថវិកាជាតិនៃខែសីហាមាន**អតិរេក ៨២** ពាន់លានរៀល ស្មើនឹង ៩១លានដុល្លារ ស.រ.អា* ។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហា ឆ្នាំ២០១២ មានលក្ខណៈដូចខាងក្រោម៖

- រូបិយវត្ថុ $M_2$ មានចំនួន ២៦ ៩៩៩ ពាន់លានរៀល កើនឡើង ០,៨% ធៀបនឹងខែមុន និងកើនឡើង ១៩ %ធៀបនឹងខែដូចគ្នាឆ្នាំមុន។

- កំណើនរូបិយវត្ថុ $M_2$ ធៀបនឹងខែមុន បណ្តាលមកពីរូបិយវត្ថុក្រៅធនាគារកើនឡើង០,៣% ប្រាក់បញ្ញើចរន្តកើន ឡើង ១៥% និងប្រាក់បញ្ញើជារូបិយបណ្ណ កើនឡើង ០,៨%។

- យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**នៅក្នុងនិងក្រៅធនាគារ**មានចំនួន ១៧ %នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣ ។%

ក្រាហ្វ៣ៈសមាសធាតុរូបិយវត្ថុ ខែសីហា ឆ្នាំ២០១២



| សមាមាត្រចំនួនប្រាក់រៀល ទៅនឹងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ប្រាក់រៀលសរុបនៅក្នុង និងក្រៅធនាគារ | ១៩,២% | ១៨,៣% | ១៩,៦% | ១៩,៣% | ១៨,៦% | ១៨% | ១៧% | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,២% | ១៥,២% | ១៥,៣% | ១៤,៨% | ១៤,៧% | ១៤% | ១៤% | | | | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ សីហា២០១២: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




- **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣១៩៦ **លានដុល្លារ** កើនឡើង ០,៩% ធៀបនឹងខែមុន និងកើនឡើង ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន **៩៣០៧ ពាន់លានរៀល** កើនឡើង ១% ធៀបនឹងខែមុន និងកើនឡើង ២០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** កើនឡើង*ជាលំដាប់* ។ ក្នុងខែនេះមានចំនួន **២០៨៤២ ពាន់លានរៀល** កើនឡើង ១,១% ធៀបនឹងខែមុន និងកើនឡើង ៣១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មានចំនួន **៣១៣០ ពាន់លានរៀល** កើនឡើង ៣% ធៀបនឹងខែមុន និងកើនឡើង ៣៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែសីហា៖

| *ប្រភេទអត្រាការប្រាក់* | *សីហា ២០១២* | *កក្កដា ២០១២* | *សីហា ២០១១* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៥,៧៩% | ៦,៥២% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១២,១២% | ២២,៤១% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ៤,៤៣% | ៤,៣៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | មិនទាន់មានតួលេខ | ១២,១១% | ១៦,៧២% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែសីហា ឆ្នាំ២០១២ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

- **កសិកម្ម៖**
  - ✓ ផលិតកម្មនេសាទមានចំនួន ៣៩ពាន់តោន កើនឡើង៨៦% ធៀបនឹងខែមុន និងស្ថិតនៅថេរធៀបនឹងខែដូចគ្នាឆ្នាំមុន។

**ឧស្សាហកម្ម៖**

- ✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយ**អគ្គិសនីកម្ពុជា**មានចំនួន ២៩២ GWh កើនឡើង៥% ធៀបនឹងខែមុន និងកើនឡើង២៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន ៩៦ GWh កើនឡើង ៥៩% ធៀបនឹងខែមុន និងកើនឡើង ៩១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤៤៤ លានដុល្លារ កើនឡើង៩% ធៀបនឹងខែមុន និងកើនឡើង ៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន— សីហា ២០១២ | ចំនួន—កក្កដា ២០១២ | ចំនួន—សីហា ២០១១ |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ១១ | ១៧ | ៨ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៥ | ៨ | ២១ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ២៤ | ៧ | ១៧ |

**សម្គាល់៖ តួលេខខាងលើនេះ ជាការចុះបញ្ជីនៅក្រសួងឧស្សហកម្មប៉ុណ្ណោះ ( ECOSOCC នឹងធ្វើបច្ចុប្បន្នភាពតួលេខដែលគ្របដណ្តប់ទូទាំងប្រទេស នៅពេលក្រោយបន្ទាប់ពីទទួលបានការបំពេញតួលេខពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមសំណូមពររបស់ ECOSOCC)។**

**សំណង់** (ការអនុញ្ញាត)៖

- ✓ សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៤៣៥ ពាន់ម² ថយចុះ ៧៣% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹងចំនួន ១៤៧ លានដុល្លារ ថយចុះ ៧២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន៖

| ប្រភេទ | ពាន់ម² —សីហា ២០១២ | ពាន់ម² —កក្កដា២០១២ | ពាន់ម² —សីហា ២០១១ |
|---|---|---|---|
| ▪ លំនៅឋាន | ២០១ | ១១៧៩ | ២៧៩ |
| ▪ ឧស្សាហកម្ម | ១០៥ | ៣៩៨ | ៦៥ |
| ▪ ពាណិជ្ជកម្ម | ៨៦ | ៩ | ៩ |
| … | | | |
| អនុញ្ញាតសរុប | ៤៣៥ | ១៦៣៩ | ៣៨២ |

- ✓ **សំណង់ដែលពេញនិយមនាខែនេះគឺ** សំណង់លំនៅឋាន នៃផ្ទៃក្រឡា ៤៦%)អនុញ្ញាតសរុប( ឧស្សាហកម្ម នៃផ្ទៃក្រឡា ២៤%)អនុញ្ញាតសរុបនិងពាណិជ្ជកម្ម ( នៃផ្ទៃក្រឡា ២០%)អនុញ្ញាតសរុប( ។

**ការងារ៖**

| ប្រភេទ | ចំនួន (នាក់)—សីហា ២០១២ | %∆ ធៀបនឹងខែមុន | %∆ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ២៣២១ | -១១% | -៣១% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៤៥៥៦ | ២០%+ | ២៦%+ |
| អ្នកទទួលបានការងារក្នុងប្រទេស | ២៥១៧ | ៦១%+ | ៨១%+ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២០៣៩ | -១៥% | -៨% |

**វិនិយោគ៖**

✓ គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែសីហាមានចំនួន ២៣ គម្រោង ដែលជាទុនវិនិយោគស្មើនឹង ១៩១ **លានដុល្លារ**។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន ៣៤ ពាន់នាក់។

| ប្រភេទ | សីហា២០១២ | កក្កដា២០១២ | សីហា២០១១ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ១៩១ | ១៨០ | ៤៧ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៩៨ | ៤៧ | ០ |
| វិស័យឧស្សាហកម្ម | ៨៧ | ១៣៣ | ៤៧ |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៥ | ០ | ០ |
| **ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន)** | ២៣ | ២១ | ១៤ |
| **បង្កើតការងារ (ពាន់នាក់)** | ៣៤ | ៣១ | ១៩ |

**សេវាកម្ម និងទេសចរណ៍៖**

✓ **ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន—សីហា ២០១២ | ចំនួន—កក្កដា ២០១២ | ចំនួន—សីហា ២០១១ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣១១ | ២៩៥ | ២៨៥ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៧ | ២ | ១ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២១៣ | ២២៥ | ៣៣២ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ៤៩៥ ពាន់តោន កើនឡើង ៧% ធៀបនឹងខែមុន និងកើនឡើង ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ: -៣% | (+៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង: +៤១% | (-១១%) |
| ▪ កំពង់ផែកំពង់សោម: -២% | (+១៥%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +៥០% | (+២៣៧%) |

**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៧,៩ | +៤៥% | +៥% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ១៣ | +៩% | +២៨% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៣២០ | +១០% | +៧% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៥ | -១% | -១៣% |
| ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៩៤ | +៣% | +១៧% |
| ✓ តាមផ្លូវអាកាស | ១៣៦ | +៨% | +១០% |
| ✓ តាមផ្លូវគោក និងទឹក | ១៥៨ | 0% | +២៥% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ **ការនាំចូល**នាខែសីហាមានចំនួន ២ ៥៩៩ ពាន់លានរៀល (ស្មើនឹង ៦៤៣លានដុល្លារ ស.រ.អា.) ថយចុះ១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងម៉ាស៊ូត | +៤% | +២៨% | ប្រេងសាំង | -១៨% | -៨% |
| រថយន្តសរុប (ព.ល.រ) | +៧% | +៣៧% | ប្រេងខ្មៅ | -២៩% | -២៦% |
| រថយន្តសរុប (គ្រឿង) | +១១% | +៣៧% | ឧស្ម័ន | -៩% | +២៤% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +៧៤% | +៥៤% | ដែកសំណង់ | -២៥% | +៩៥% |
| ម៉ូតូ (គ្រឿង) | +២៦% | +៣៥% | គ្រឿងអេឡិចត្រូនិក | +៨% | -៣៤% |
| ផ្លែឈើ និងបន្លែ | +៣៦៩% | +៣០៥% | ស៊ីម៉ង់ត៍ | -៣៧% | +៣៧% |
| អង្ករ | -៤៧% | +១១៨២៥% | ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១% | +២០% |

➡ **ការនាំចេញ** ក្នុងខែសីហាឆ្នាំ២០១២ មានចំនួន ២៣១០ពាន់លានរៀល ស្មើនឹង ៥៧១លានដុល្លារ ស.រ.អា. (៨៩% នៃការនាំចូល) កើនឡើង១០% ធៀបនឹងខែមុន និងកើនឡើង២៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែឆ្នៃ | -៥២% | -៩៨% | ផលិតផលនេសាទ | -៨២% | -៩៣% |
| វាយនភណ្ឌនិងស្បែកជើង | +១៦% | +៥៦% | កៅស៊ូ | -២៨% | +១៣% |
| អង្ករ | +៣៤% | +៣៣% | | | |

➡ ក្នុងខែសីហានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ២៩០ ពាន់លានរៀល ស្មើនឹង ៧២ លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហា ឆ្នាំ២០១២នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃសាច់គោស្រស់ | +២,៥% | +១៣% | — |
| ២ | ថ្លៃបន្លែ | +១% | +១៤% | — |
| ៣ | ការនាំចូលអង្ករ (៤១,២ ពាន់តោន) | -៤៧% | កើនយ៉ាងគំហុក | កាលពីខែកក្កដាកម្ពុជានាំចូលអង្ករចំនួន ៧៨,២ ពាន់តោន។ |
| ៤ | ការនាំចេញអង្ករ (១៩,៤ ពាន់តោន) | +៣៤% | +៣៣% | សម្រាប់៨ខែ ឆ្នាំ២០១១ តួលេខនាំចេញអង្ករស្មើនឹង ១១០,១ ពាន់តោន។ |
| ៥ | ការនាំចូលបន្លែ និងផ្លែឈើ (៩,៣ ពាន់តោន) | +៣៦៩% | +៣០៥% | កម្ពុជានាំចូលបន្លែ និងផ្លែឈើ ប្រហែល ៥០% នៃតម្រូវការក្នុងស្រុក។ |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

បន្លែមានថ្លៃខ្ពស់និងឡើងថ្លៃជាប្រចាំ នេះបណ្តាលមកពីការផ្គត់ផ្គង់ក្នុងស្រុកទាបជាងតម្រូវការ។ បច្ចុប្បន្នកម្ពុជាពឹងផ្អែកលើការនាំចូលបន្លែនិងផ្លែឈើពីប្រទេសជិតខាងប្រហែលពាក់កណ្តាលនៃតម្រូវការសរុប។

- ការដាំបន្លែនិងផ្លែឈើ ភាគច្រើនជាលក្ខណៈគ្រួសារខ្នាតតូច ដែលមានសមត្ថភាពផ្គត់ផ្គង់ទាប
- តម្រូវការកើនឡើងជាប្រចាំដោយសារកំណើនប្រជាជន និងទេសចរណ៍
- ខ្វះបច្ចេកទេស និងគោលនយោបាយ

***ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖***

ដើម្បីឆ្លើយតបនឹងតម្រូវការដែលចេះតែកើនឡើង ការដាំបន្លែនិងផ្លែឈើ ត្រូវតែមានលក្ខណៈទ្រង់ទ្រាយធំ ប្រកបដោយបច្ចេកទេសខ្ពស់។ គោលនយោបាយជំរុញកសិកម្មខ្នាតធំគួរបានកំណត់ឡើង ដោយមានយុទ្ធសាស្ត្រទាក់ទាញវិនិយោគ លើកទឹកចិត្ត និងធានាការគាំទ្របច្ចេកទេស។

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១២<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយរបាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៣។<br>២-ផ្សព្វផ្សាយផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ ២០១៣។ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ២ | ០៣/០៩/១២<br>ម៉ោង ១៤ : ០០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីទទួលដំណើរគណៈប្រតិភូជាន់ខ្ពស់ នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងធ្វើដំណើរមកមាតុភូមិនិវត្តន៍ជាផ្លូវការ ពីទីក្រុងតេអេរ៉ង់ នៃសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងទីក្រុងអ៊ូរូមហ្គី នៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ៣ | ០៤/០៩/១២<br>ម៉ោង ០៧ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជូនដល់និស្សិត នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៤ | ០៤/០៩/១២<br>ម៉ោង ១៥ : ៣០ នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធសៀងបម្រុងកម្ពុជា។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៥/០៩/១២<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សាសាលាមត្តេយ្យឈុងជីងថ្មី និងពិសាភោជនាហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលាមត្តេយ្យឈុងជីង។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៦ | ០៥/០៩/១២<br>ម៉ោង ១៦ : ៣០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ០៦/០៩/១២<br>ម៉ោង ០៩ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូណេស្កូ ស្តីពីផែនការប្រតិបត្តិការគម្រោង Funds-In-Trust សម្រាប់ជួសជុល និងអភិរក្សជណ្តើរកសិណ ប្រាសាទអង្គរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ០៧/០៩/១២<br>ម៉ោង ១០ : ០០នាទី | ជួបប្រជុំពិភាក្សាជាមួយ ឯកឧត្តម **អ៊ឹម ឈុន** នៅបន្ទប់ឯកឧត្តមប្រធាន ECOSOCC នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១១/០៩/១២<br>ម៉ោង ០៨ : ០០នាទី | ប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនសិប្បករអង្គរ (Artisan Angkor) នៅខេត្តសៀមរាប។ |
| ១០ | ១២/០៩/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីថាមពលអាស៊ាន លើកទី៣០ និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងវេទិកាធុរកិច្ចថាមពលអាស៊ាន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១១ | ១៧/០៩/១២<br>ម៉ោង ១៥ : ៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទីនិងភារកិច្ច នៃសហគមន៍កសិករប្រើប្រាសទឹក។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃសេវាសាធារណៈ។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ឈុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | ១៨/០៩/១២<br>ម៉ោង ១៦ : ០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិប តីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាសទឹក។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃសេវាសាធារណៈ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៩/០៩/១២<br>ម៉ោង ១៦ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតអន្តរជាតិលើកទី២ របស់វិទ្យាស្ថាន ខុងជឺ ស្តីពី "៥៥ឆ្នាំនៃទំនាក់ទំនងកម្ពុជា-ចិន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ១៤ | ២០/០៩/១២<br>ម៉ោង ០៨ : ០០នាទី | ចូលរួមជាគណៈអធិបតី ក្នុងពិធីប្រគល់ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២-២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៥ | ២១/០៩/១២<br>ម៉ោង ១៦ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលើកទី ៤ នៃកិច្ចព្រមព្រៀងស្តីពីគម្រោងកំណើន សេដ្ឋកិច្ចជាមួយ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២២/០៩/១២<br>ម៉ោង ០៧ : ០០នាទី | ចូលរួមអបអរសាទរខួបលើកទី១៤៩ ទិវាពិភពលោកកាកបាទក្រហមអឌ្ឍចន្ទក្រហម៨ ឧសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅបរិវេណលេខាធិការដ្ឋានក្រុមប្រឹក្សាខេត្តតាកែវ។ |
| ១៧ | ២២/០៩/១២<br>ម៉ោង ១០ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះបឋមសិលា បើកការដ្ឋានសាងសង់សាលារៀនអឺស្លាម ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅភូមិត្រពាំងលើក ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ។ |
| ១៨ | ២៥/០៩/១២<br>ម៉ោង ០៧ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជំនាន់ទី ១៥ និង ១៦ និងថ្នាក់បរិញ្ញាបត្រ ជាន់ខ្ពស់ជំនាន់ទី ១០ និង ១១ ជូនដល់និស្សិត សាកលវិទ្យាល័យជាតិគ្រប់គ្រង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៩ | ២៥/០៩/១២ ម៉ោង ១៧ : ០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក MENANTEAU CEO ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៦/០៩/១២ ម៉ោង ១៨ : ៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបុណ្យជាតិចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសណ្ឋាគាររ៉ាំងទេរកុងទីណង់តាល់។ |
| ២១ | ២៧/០៩/១២ ម៉ោង ០៨ : ០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវអគារសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលាដំបូងរាជធានីភ្នំពេញ ទល់មុខពហុកីឡដ្ឋានជាតិអូឡាំពិក។ |
| ២២ | ២៧/០៩/១២ ម៉ោង ១៥ : ៣០នាទី | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ២៣ | ២៨/០៩/១២ ម៉ោង ០៨ : ៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាការពារជាតិ។<br>២-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មា ធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។<br>៤-បញ្ហាផ្សេងៗ៖សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៤.១-កិច្ចព្រមព្រៀងស្តីពីការបង្កើតវិទ្យាស្ថានអភិវឌ្ឍន៍បៃតងសកល។<br>៤.២-អនុសញ្ញាអន្តរជាតិស្តីពីនិយតកម្ម នៃការនេសាទបាឡែន។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២៤ | ២៨/០៩/១២ ម៉ោង ១៥ : ០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គីភ័យ។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យជាចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយរបាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣។<br>២-ផ្សព្វផ្សាយផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ ២០១៣។ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ២ | ០៥/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សាសាលាមត្តេយ្យឈូងជីង ថ្មី និងពិសាភោជនាហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលាមត្តេយ្យឈូងជីង។ |
| ៣ | ០៦/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូណេស្កូ ស្តីពីផែនការប្រតិបត្តិការគម្រោង Funds-In-Trust សម្រាប់ជួសជុល និងអភិរក្សជណ្តើរកសិណ ប្រាសាទអង្គរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៩/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតអន្តរជាតិលើកទី ២ របស់វិទ្យាស្ថាន ខុងជឺ ស្តីពី “៥៥ឆ្នាំ នៃទំនាក់ ទំនងកម្ពុជា-ចិន” ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៥ | ២១/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលើកទី ៤ នៃកិច្ចព្រមព្រៀងស្តីពីគម្រោងកំណើន សេដ្ឋកិច្ចជាមួយ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២៧/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវអគារសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលាដំបូងរាជធានីភ្នំពេញ ទល់មុខ ពហុកីឡដ្ឋានជាតិអូឡាំពិក។ |

# សកម្មភាពផ្សេងទៀតរបស់ ឯកឧត្តម អនុប្រធាន ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២

## ឯកឧត្តម ឌុយ ធៅ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តតាកែវ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយរបាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣។<br>២-ផ្សព្វផ្សាយផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ ២០១៣។ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ២ | ០៥/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សាសាលាមត្តេយ្យឈុងជីង ថ្មី និងពិសាភោជនាហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលាមត្តេយ្យឈុងជីង។ |
| ៣ | ០៦/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូណេស្កូ ស្តីពីផែនការប្រតិបត្តិការគម្រោង Funds-In-Trust សម្រាប់ជួសជុល និងអភិរក្សជណ្តើរកសិណ ប្រាសាទអង្គរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៨/០៩/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការវាយតម្លៃសេវាសាធារណៈ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ២១/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលើកទី ៤ នៃកិច្ចព្រមព្រៀងស្តីពីគម្រោងកំណើន សេដ្ឋកិច្ចជាមួយ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ២៧/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវអគារសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅសាលាដំបូងរាជធានីភ្នំពេញ ទល់មុខ ពហុកីឡាដ្ឋានជាតិអូឡាំពិក។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អគ្គលេខាធិការ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១២

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារចុះជួយមូលដ្ឋានខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តតាកែវ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-ផ្សព្វផ្សាយរបាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៣។<br>២-ផ្សព្វផ្សាយផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ ២០១៣។ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ខេត្តតាកែវ។ |
| ២ | ០៥/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធអគារសិក្សាសាលាមត្តេយ្យឈុងជីង ថ្មី និងពិសាភោជនាហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ នៅសាលាមត្តេយ្យឈុងជីង។ |
| ៣ | ០៦/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការយូណេស្កូ ស្ដីពីផែនការប្រតិបត្តិការគម្រោង Funds-In-Trust សម្រាប់ជួសជុល និងអភិរក្សជណ្ដើរកសិណ ប្រាសាទអង្គរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៨/០៩/១២ | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្ដីព្រាងព្រះរាជក្រឹត្យស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង។<br>២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីនីតិវិធី នៃការបង្កើត ការរំលាយចោលតួនាទី និងភារកិច្ច នៃសហគមន៍កសិករប្រើប្រាស់ទឹក។<br>៣-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការវាយតម្លៃសេវាសាធារណៈ។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ១៩/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតអន្តរជាតិលើកទី ២ របស់វិទ្យាស្ថាន ខុងជឺ ស្ដីពី "៥៥ឆ្នាំ នៃទំនាក់ ទំនងកម្ពុជា-ចិន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅរាជបណ្ឌិតសភាកម្ពុជា។ |
| ៦ | ២១/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីចុះហត្ថលេខាលើវិសោធនកម្មលើកទី ៤ នៃកិច្ចព្រមព្រៀងស្ដីពីគម្រោងកំណើន សេដ្ឋកិច្ចជាមួយ USAID ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ២៧/០៩/១២ | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវអគារសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅសាលាដំបូងរាជធានីភ្នំពេញ ទល់មុខ ពហុកីឡាដ្ឋានជាតិអូឡាំពិក។ |

# សិក្ខាសាលាស្តីពី ពិធីការផ្សព្វផ្សាយគម្រោងវិភាគលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត

## សណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា ថ្ងៃពុធ ទី៣ ខែតុលា ឆ្នាំ២០១២

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០១២ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងធនាគារអភិវឌ្ឍន៍អាស៊ី(ADB) តាមរយៈក្រុមហ៊ុន POHL Consulting & Associates បានរួមគ្នារៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយគម្រោងវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា ដែលឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នឹងធ្វើជាអធិបតីក្នុងពិធីបិទអង្គសិក្ខាសាលានេះនៅពេលល្ងាច។




ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ថ្លែងសុន្ទរកថាក្នុងពិធីបិទអង្គសិក្ខាសាលា

វាគ្មិននៅក្នុងព្រឹត្តិការណ៍ពេញមួយថ្ងៃនេះ រួមមានឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ហើយឯកឧត្តមទេសរដ្ឋមន្ត្រីក៏នឹងធ្វើជាអធិបតីក្នុងពីធីបើកនេះផងដែរ បន្ទាប់មកមានលោកជំទាវ **ស៊ីហ្គេគូ ហាថូរី** (Shigeko Hattori) នាយកផ្នែកគ្រប់គ្រងសារធាណៈ វិស័យហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ប្រចាំតំបន់អាស៊ីអាគ្នេយ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី នឹងផ្តល់ចំណាប់អារម្មណ៍ក្នុងពីធីបើក ចំណែកឯកឧត្តម Eric Sidgewick នាយកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជា នឹងមានចំណាប់អារម្មណ៍ក្នុងពិធីបិទ។ ហើយនៅមានវាគ្មិនមួយ

ចំនួនទៀតដូចជា ឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA លោកបណ្ឌិត **ខេលី ប៊ឺត** (Dr. Kelly Bird) ឧត្តមសេដ្ឋវិទូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រធានគ្រប់គ្រងគម្រោង RIA លោក **សាបេស ស៊ីវ៉ាសាបេសាន** (Sabesh Shivasabesan) ប្រធានក្រុមទីប្រឹក្សាក្រុមហ៊ុន POHL លោក **រូប៊ឺត ខឺរ** (Robert Kerr) អ្នកឯកទេសRIAនៅអូស្ត្រាលី បណ្ឌិត **ង្វៀន ឌីញខុង** (Nguyen Dinh Cung) អ្នកឯកទេសRIAនៅវៀតណាម និងមានវាគ្មិនមកពីក្រសួងពាក់ព័ន្ធមួយចំនួនទៀត។



ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធាន ECOSOCC ថ្លែងសុន្ទរកថាក្នុងពិធីបើកអង្គសិក្ខាសាលា

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ជាការវិភាគមានលក្ខណៈជាប្រព័ន្ធលើសំណើបញ្ញត្តិកម្ម វាជាឧបករណ៍ ឬវិធីសាស្ត្រ ដែលត្រូវបានប្រើប្រាស់សម្រាប់ការតាក់តែងបញ្ញត្តិកម្មឲ្យបានល្អ ដែលលើកកំពស់ប្រសិទ្ធភាពបញ្ញត្តិកម្ម និងគោលនយោបាយប្រកួតប្រជែង។ ការវិភាគនេះ ក៏ធ្វើឲ្យប្រសើរឡើងផងដែរនូវតម្លាភាព និងអភិបាលកិច្ចល្អ។ នៅប្រទេសកម្ពុជា RIA អាស្រ័យលើការវិភាគដោយផ្អែកលើសុភវិនិច្ឆ័យ និងកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ។ RIA ក៏ជាឯកសារដែលកត់ត្រាពីលទ្ធផលនៃដំណើរការវិភាគផងដែរ។



គម្រោង RIA ទទួលហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី ហើយគម្រោងនេះគឺជាផ្នែកមួយនៃកម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច " Promoting Economic Diversification " (PED) របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ កម្មវិធីជំរុញពិពិធកម្មសេដ្ឋកិច្ច គាំទ្រដល់អាទិភាពកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលមានបំណងធ្វើពិពិធភាពនៃប្រភពកំណើនសេដ្ឋកិច្ច។

ECOSOCC ជាអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី និងជាទីភ្នាក់ងារប្រតិបត្តិគម្រោងនេះ។ ដោយមានក្រុមការងារអនុវត្តគម្រោងRIAគម្រោងវិភាគលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (ORIA) ជាទីភ្នាក់ងារត្រួតពិនិត្យគម្រោងដែលត្រូវបានបង្កើតឡើងនៅក្នុង ECOSOCC។ ក្រសួងពាក់ព័ន្ធចំនួនបួនរួមមានក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងទេសចរណ៍ បានចូលរួមក្នុងគម្រោងនេះជាទីភ្នាក់ងារអនុវត្ត។



ឯកឧត្តម **យឹម ណុលសន** អនុប្រធាន ECOSOCC និងជានាយកគម្រោង RIA ធ្វើសេចក្តីរាយការណ៍ជូនអង្គសិក្ខាសាលា

គម្រោង RIA បាននិងកំពុងមានការរីកចម្រើនគួរឲ្យកត់សម្គាល់ ចាប់តាំងពីពេលចាប់ផ្តើមគម្រោងមកម្ល៉េះ។ របាយការណ៍ចាប់ផ្តើមគម្រោងដែលបង្ហាញពីផែនការសម្រាប់ការអនុវត្តគម្រោង RIA ត្រូវបានបោះពុម្ពផ្សាយនៅខែធ្នូ ឆ្នាំ២០១១។ អំពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា ទម្រង់វាយតម្លៃបឋម (PA) និងបញ្ជីត្រួតពិនិត្យ (checklist) បានបោះពុម្ពផ្សាយទាំងជាភាសាអង់គ្លេស និងភាសាខ្មែរ នៅពាក់កណ្តាលឆ្នាំ២០១២ នេះ។

សំណើបញ្ញត្តិកម្មមួយចំនួន ត្រូវបានយកមកវិភាគតាមវិធីសាស្ត្រRIA។ ប្រធានទីភ្នាក់ងារអនុវត្តគម្រោងនីមួយៗ បានធ្វើបទបង្ហាញពីការងារវិភាគរបស់ពួកគាត់នាពេលរសៀលនៃពិធីផ្សព្វផ្សាយនេះ។ ហើយបន្ទាប់មកក៏មានកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ផងដែរ។ ហើយនៅចុងបញ្ចប់នៃពិធីផ្សព្វផ្សាយនេះ នឹងមានការបូកសរុបលទ្ធផលនៃអង្គសិក្ខាសាលាដោយឯកឧត្តម **យឹម ណុលសន** ព្រមទាំងចំណាប់អារម្មណ៍របស់ឯកឧត្តម Eric Sidgwick និងបន្ទាប់មកមានសន្ទរកថាបិទអង្គសិក្ខាសាលាដោយ ឯកឧត្តមបណ្ឌិត សភាចារ្យ **សុខ អាន** ។

នាពេលអនាគតដ៏ខ្លីខាងមុខនេះ គម្រោង RIAនឹងរៀបចំឲ្យមានសកម្មភាពផ្សព្វផ្សាយនៅតាមគ្រឹះស្ថានជាន់ខ្ពស់មួយចំនួនទៀត ដើម្បីបញ្ជ្រាបទស្សនទាន RIA ។

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡៃន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ខ៉ាន់ គិរុណា | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង រត្នមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ឆារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត ភក្តដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in